# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបក្រុមបេសកកម្មវាយតម្លៃអាស៊ាន របស់អង្គការ **GIZ** អាល្លឺម៉ង់



នៅរសៀលថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបក្រុមបេសកកម្មវាយតម្លៃអាស៊ាន របស់អង្គការ GIZ នៃប្រទេសអាល្លឺម៉ង់ **(GIZ ASEAN Appraisal Mission)** ដឹកនាំដោយលោក **Karl Bartel** នាយកគ្រប់គ្រងគម្រោងជាន់ខ្ពស់នៃនាយកដ្ឋានអាស៊ីបូព៌ា និង ប៉ាស៊ីហ្វិក នៃអង្គការ GIZ អាល្លឺម៉ង់ ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Karl Bartel** នាយកគ្រប់គ្រងគម្រោងជាន់ខ្ពស់នៃនាយកដ្ឋានអាស៊ីបូព៌ា និង ប៉ាស៊ីហ្វិក នៃអង្គការ GIZ អាល្លឺម៉ង់ បានជម្រាបជូនថាៈ ក្រុមបេសកកម្មរបស់លោកធ្វើការងារទាក់ទង និងវិស័យសហគ្រាសធុនតូច និងមធ្យម (SME) ក្នុងតំបន់អាស៊ាន ក្រោមគម្រោងថ្នាក់តំបន់ដែលមានឈ្មោះថាៈ**កិច្ចពង្រឹងរចនាសម្ព័ន្ធថ្នាក់តំបន់សម្រាប់ការលើកកំពស់សហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងតំបន់អាស៊ាន (Strengthening Regioanal Structures for Small and Meduim Enterprise Promotion in the ASEAN Region )** ដែលបានកំណត់ឡើង ដើម្បីអនុវត្តយុទ្ធសាស្ត្រផែនការសកម្មភាពសហគ្រាសធុនតូច និងមធ្យមអាស៊ានពីឆ្នាំ២០១៦–២០២៥ ដោយផ្តោតជាសំខាន់ទៅលើវិស័យជាក់លាក់មួយចំនួនរួមមាន : –កិច្ចសហប្រតិបត្តិការក្នុងតំបន់–សេវាព័ត៌មានជាតិ–ការផ្ទេរបច្ចេកវិទ្យា និងការគាំទ្រកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីគោលនយោបាយសហគ្រាសខ្នាតតូចនិងមធ្យម ។ ជំនួបនាថ្ងៃនេះ លោក **Karl Bartel** បានជម្រាបថាៈក្រុមបេសកកម្មរបស់លោក ចង់ស្វែងយល់ពីគោលនយោបាយ ទំនាក់ទំនង និងអ្វីដែលជាតម្រូវការរបស់កម្ពុជា ទាក់ទងនិងការលើកកំពស់វិស័យសហគ្រាសខ្នាតតូចនិងមធ្យម ។



ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និង បានជម្រាបថា:សហគ្រាសធុនតូច និងមធ្យម បានដើរតួរសំខាន់ណាស់ ក្នុងចរន្តសេដ្ឋកិច្ចកម្ពុជា ជាពិសេសក្នុងបរិបទនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ឯកឧត្តម បានបញ្ជាក់ថា: បច្ចុប្បន្ននៅកម្ពុជាវិស័យ SME មានជាង៥0 ម៉ឺនមូលដ្ឋាន ហើយវិស័យនីមួយៗមានការពាក់ព័ន្ធជាមួយក្រសួង–ស្ថាប័នជាច្រើន ។ កន្លងនេះ ទើបក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានបង្កើតជាបន្តបន្ទាប់ ដូចជា:ច្រកចេញចូលតែមួយ និងសេវាក្រោមដំបូលតែមួយ ជាដើម ក្នុងន័យឱ្យសហគ្រាសខ្នាតតូច និងមធ្យម អាចមកចុះបញ្ជីទទួលស្គាល់ឱ្យបានជាអតិបរមា ដើម្បីឱ្យមានការទទួលស្គាល់តាមផ្លូវច្បាប់ ហើយងាយស្រួលគ្រប់គ្រង និងអភិវឌ្ឍន៍ ។ ក៏ប៉ុន្តែ បច្ចុប្បន្ន ការមកចុះបញ្ជីរបស់សហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ជាសរុបបានប្រមាណជា១៥%ប៉ុណ្ណោះ ដោយសារខ្វះការយល់ដឹងទូលំទូលាយ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានជម្រាបជូនពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកំពស់វិស័យ SME ដូចជា:តាមរយ:ការបង្កើតក្រុមការងាររាជរដ្ឋាភិបាល និងវិស័យឯកជន –ផ្តល់ការយកចិត្តទុកដាក់ទៅលើការបង្កើត សម្ព័ន្ធវីសមាគមសហគ្រាសខ្នាតតូចនិងមធ្យម–ពង្រឹងសភាពាណិជ្ជកម្មកម្ពុជា ដែលធ្វើការងារទាក់ទងនិងវិស័យ SME –ការធ្វើប្រតិភូកម្មអំណាច ទៅថ្នាក់ក្រោមជាតិ–ពង្រឹងអនុវត្តការផ្តល់សេវាតាមច្រកចេញចូលតែមួយ និងការអនុវត្តក៏ចុះបញ្ជីតាមប្រព័ន្ធ Online ជាដើម ។ ជាពិសេសថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា ទើបប្រកាសដាក់ឱ្យប្រើនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ពីឆ្នាំ២0១៥–២0២៥ ។ ក្នុងនោះវិស័យអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមស្ថិត ក្នុងសសរស្តម្ភ

សំខាន់ផងដែរ ។ ក្រោពីនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានជម្រាបជូនពីអង្គភាពចំណុះមួយចំនួនរបស់ក្រសួង ដែលធ្វើការងារទាក់ទង និងការពង្រឹង– ការបណ្តុះបណ្តាល និងវាយតម្លៃទៅលើសមត្ថភាព SME នៅកម្ពុជា ដូចជា៖ វិទ្យាស្ថានស្តង់ដារកម្ពុជា–មជ្ឈមណ្ឌលផលិតភាពជាតិ និងនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ជាដើម ។

ជាមួយនិងការវាយតម្លៃខ្ពស់ និងផ្តល់សារៈសំខាន់ ទៅលើសកម្មភាពជាគោលដៅ នៃគម្រោងថ្នាក់តំបន់របស់អង្គការ GIZ អាល្លឺម៉ង់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បាស្នើឱ្យអង្គការ GIZ យកចិត្តទុកដាក់ជួយដល់កម្ពុជា លើចំណុចអាទិភាពមួយចំនួន មានដូចជា៖ការបណ្តុះបណ្តាលធុនធានមនុស្ស–ពង្រឹងសមត្ថភាពវិស័យរោងចក្រសហគ្រាស–ផ្តល់ជំនាញគ្រប់គ្រង និងការកែឆ្នៃ–ការផ្តល់ជំនួយបច្ចេកទេស–ការផ្ទេរបច្ចេកវិទ្យា–ការចែករំលែកនិងការទទួលបានព័ត៌មាន–បណ្តាញទំនាក់ទំនង និង សម្របសម្រួលថ្នាក់តំបន់ ជាដើម ។